**មាត្រា ២** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សាមីរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០០

**សេចក្តីសំរេចលេខ ០២ សសរ**

**ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង**

**ដើម្បីស្រាវជ្រាវបទល្មើសព្រៃឈើ នៅខេត្តមណ្ឌលគិរី**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីប្រកាសលេខ ០១/ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩ ស្តីពីវិធានការគ្រប់គ្រង និង លុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មការចំរុះអន្តរក្រសួងមួយ ដើម្បីស្រាវជ្រាវការប្រព្រឹត្តិបទល្មើសព្រៃឈើ នៅក្នុងខេត្តមណ្ឌលគិរី ដែលមានសមាសភាព ដូចខាងក្រោម ៖

-ឯកឧត្តម **ឃុន ហាំង** រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជាប្រធាន

-ឯកឧត្តម **ព្រុំ សុខា** និងឯកឧត្តម **ចាន់ ស៊ីណា** សហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន

-ឯកឧត្តម **ចាយ សាំងយុន** និងឯកឧត្តម **ម៉ៅ ម៉ិនស្រ៊ី** សហរដ្ឋលេខាធិការក្រសួងការពារជាតិ

ជាអនុប្រធាន

-ឯកឧត្តម ស៊ុយ នូ រដ្ឋលេខាធិការក្រសួងវប្បធម៌ ជាសមាជិក
-ឯកឧត្តម ច័ន្ទ តុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក
-ឯកឧត្តម ឆាន់ សារ៉ាន រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាសមាជិក
-ឯកឧត្តម កែ គឹមយ៉ាន អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ជាសមាជិក
-ឯកឧត្តម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិនៃក្រសួងមហាផ្ទៃ ជាសមាជិក
-ឯកឧត្តម យ៉េង ម៉ារ៉ាឌី អគ្គាធិការកិច្ចការនយោបាយនិងរដ្ឋបាលនៃក្រសួងមហាផ្ទៃ ជាសមាជិក
-ឯកឧត្តម ប្រាជ្ញ ចន្ទ អគ្គនាយករដ្ឋបាល នៃក្រសួងមហាផ្ទៃ ជាសមាជិក
-ឯកឧត្តម សៅ សុខា មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិក
-លោក គល់ សារម៉ែន តំណាងលេខាធិការដ្ឋានអង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ ជាសមាជិក

ប្រការ ២ : គណៈកម្មការដែលមានសមាសភាពខាងលើនេះ មានភារកិច្ចបំពេញបេសកកម្មដូចតទៅ ៖

ក- ចុះត្រួតពិនិត្យ និងស្រាវជ្រាវអោយបានច្បាស់លាស់ នូវបទល្មើសព្រៃឈើនៅក្នុងខេត្តមណ្ឌលគិរី ។

ខ- ត្រូវធ្វើរបាយការណ៍លំអិតអំពីលទ្ធផល នៃការត្រួតពិនិត្យជាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៣ : ដើម្បីសំរួលដល់បេសកកម្មនៃការត្រួតពិនិត្យស្រាវជ្រាវខាងលើនេះ ៖

-ក្រសួងមហាផ្ទៃត្រូវធ្វើសំណើសុំរាជរដ្ឋាភិបាល ផ្អាកការងារជាបណ្ដោះអាសន្ន អភិបាល និង អភិបាលរងខេត្ត មណ្ឌលគិរី ដែលមានការពាក់ព័ន្ធ និងត្រូវស្នើរាជរដ្ឋាភិបាលចាត់តាំងក្រុមការងារមួយ ដើម្បីរ៉ាប់រងការងារបន្តនៅក្នុងខេត្ត ។

-ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងវប្បធម៌ និងស្ថាប័នផ្សេងៗទៀត ត្រូវធ្វើសេចក្ដីសំរេចផ្អាកការងារជាបណ្ដោះអាសន្ន ចំពោះមន្ត្រីក្រោមឱវាទខ្លួនទាំងអស់ដែលមានការពាក់ព័ន្ធ និងធ្វើការតែងតាំងជំនួសបណ្ដោះអាសន្ន ដើម្បីរ៉ាប់រងការងារបន្ត ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាព ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០០០

## សេចក្ដីសំរេចលេខ ០៣ សសរ

## ស្ដីពីការបង្កើតគណៈកម្មការចំរុះ កម្ពុជា សហគមន៍អឺរ៉ុប

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥៩៩/០២ ចុះថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និងសហគមន៍អឺរ៉ុប
- យោងតាមសំណើរបស់ ឯកឧត្ដមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការចំរុះកម្ពុជា សហគមន៍អឺរ៉ុប មួយដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| -ឯកឧត្ដមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | ជាប្រធាន |
| -ឯកឧត្ដមរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធានទី១ |
| -ឯកឧត្ដម ខុង សំនួន អនុរដ្ឋលេខាធិការក្រសួងការបរទេស | ជាអនុប្រធានទី២ |
| -ឯកឧត្ដម ឈៀង យ៉ាំណាំ អគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| -តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| -តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| -តំណាងក្រសួងអប់រំ យុវជន និង កីឡា | ជាសមាជិក |
| -តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| -ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងការបរទេស | ទទួលបន្ទុកជាលេខាធិការ |

**ប្រការ ២ :** គណៈកម្មការនេះមានបេសកកម្មដូចខាងក្រោម :

- ធ្វើទំនាក់ទំនង និងធ្វើវេទិកាពិភាក្សាបញ្ហានានា ជាមួយសហគមន៍អឺរ៉ុបអោយបានច្រើនដើម្បីស្វែងរកជំនួយពីបណ្ដាប្រទេសមាយកនៅទ្វីបអឺរ៉ុប សំរាប់ស្ដារនិងអភិវឌ្ឍន៍ វិស័យ សេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ និងវប្បធម៌ កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ។ល។

- វាយតម្លៃឆមាស អំពីកិច្ចសហប្រតិបត្តិការរៀងរាល់ ០២ ឆ្នាំម្តងដើម្បីលើកលំនាំ និង ទិសដៅការងារកិច្ចសហប្រតិបត្តិការនៅឆ្នាំខាងមុខ ។

ប្រការ ៣ : ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការមានភារកិច្ច និង សិទ្ធិ ៖

-បង្កើតក្រុមពិសេសប្រចាំឆ្នាំ អ្នកសំរបសំរួលការងារនៃការ ដែលមកពីភាគីទាំងពីរតាមតម្រូវការ

-ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីស្នើសុំ គោលការណ៍ ឬមតិណែនាំ

-សមាជិកនៃគណៈកម្មការ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន

-មានសិទ្ធិប្រើត្រា នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តភារកិច្ចពាក់ព័ន្ធ ព្រំដែន ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងស្ថាប័នពាក់ព័ន្ធដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែមករា ឆ្នាំ ២០០០

**សេចក្តីសំរេចលេខ ០៨ សសរ**
**ស្តីពីការបង្កើតគណៈកម្មការចំរុះ អន្តរក្រសួង**
**ដើម្បីទប់ស្កាត់បទល្មើសអនាធិបតេយ្យព្រៃឈើ និង ជីករ៉ែត្បូង**
**នៅស្រុកសំឡូត ខេត្តបាត់ដំបង**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី